ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាអនុវត្តការងារ

លេខ៖ ១២/១១ FWUC_SK-ISC

គាំទ្រលើកិច្ចដំណើរការគ្រប់គ្រងបែងចែកទឹកស្រោចស្រព

និងការប្រមូលប្រាក់សេវាកម្ម

សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រ

ស្តៅកោង ខេត្តព្រៃវែង

រយៈពេលបីខែ ចាប់ពីចុងខែមេសា ឆ្នាំ២០១១ដល់ ខែកក្កដា ឆ្នាំ២០១១

សំរាប់រដូវស្រោចស្រពទី១១

**រវាង**

**គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកស្តៅកោង**

**និង**

**មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ**

**ខេត្តកំពង់ធំ**

ខែមេសា ឆ្នាំ ២០១១

# **កិច្ចសន្យាអនុវត្តការងារ**

*កំឡុងពេល ខែមេសា ឆ្នាំ២០១១ដល់ ខែកក្កដា ឆ្នាំ២០១១*
*គាំទ្រលើកិច្ចដំណើរការគ្រប់គ្រងបែងចែកទឹកស្រោចស្រព*
*និងការប្រមូលប្រាក់សេវាកម្ម សហគមន៍កសិករប្រើប្រាស់ទឹក*
*ប្រព័ន្ធធារាសាស្ត្រស្តៅកោង ខេត្តព្រៃវែង*

លេខ៖ ១២/១១ FWUC_SK-ISC

---

*កិច្ចសន្យានេះរៀបចំឡើងរវាង សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្តៅកោង ជាភាគីម្ចាស់គម្រោង ដែលតំណាងដោយ លោក* ***ស៊ឹម ស្រួយ*** *ជាប្រធានគណៈកម្មាធិការសហគមន៍ប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្តៅកោង និង មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ ជាភាគីអនុវត្តគម្រោង ដែលតំណាងដោយ លោក សេង សុភ័គ ជាអ្នកសម្របសម្រួលមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ។*

**ប្រការ ១ គោលបំណង**

មជ្ឈមណ្ឌលសេវាម្មធារាសាស្ត្រ នឹងផ្តល់សេវាកម្មជូនសហគមន៍កសិករប្រើប្រាស់ទឹកស្តៅកោង កំឡុងពេល ខែមេសា ឆ្នាំ២០១១ដល់ ខែកក្កដា ឆ្នាំ២០១១ ៖

**១.** គាំទ្រលើការគ្រប់គ្រងបែងចែកទឹកស្រោចស្រព
- រៀបចំផែនការស្រោចស្រព
- តាមដានការគ្រប់គ្រងបែងចែកទឹកស្រោចស្រព
- គាំទ្រលើដំណើរការជួសជុល និងថែទាំ

**២.** គាំទ្រការប្រមូលប្រាក់សេវាកម្ម
- រៀបចំប្រព័ន្ធទិន្នន័យក្បាលដីស្រែ
- រៀបចំ និងគាំទ្រការប្រជុំទូទៅតាមភូមិ
- រៀបចំ និងគាំទ្រការប្រមូលប្រាក់សេវាកម្ម
- បូកសរុបការប្រមូលប្រាក់សេវាកម្ម
- រៀបចំ និងគាំទ្រការប្រជុំសន្និបាតទូទៅតាមភូមិ

**ប្រការ ២ គម្រោងចំណាយលើការអនុវត្តន៍សកម្មភាពការងារក្នុងកិច្ចសន្យា**

ការចំណាយលើការអនុវត្តន៍សកម្មភាពការងារខាងលើនេះ ត្រូវបានគិតតម្លៃជាភាគរយ ចំនួន៥ ភាគរយ នៃចំនួនទឹកប្រាក់សេវាកម្មសរុបដែលប្រមូលបាន។

រាល់ការចំណាយផ្សេងៗលើការអនុវត្តន៍សកម្មភាពការងារខាងលើនេះ សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្តៅកោង ជាអ្នកទទួលខុសត្រូវ។

**ប្រការ ៣ ការបង់ប្រាក់ថ្លៃអនុវត្តសកម្មភាពការងារ**

ការបង់ប្រាក់ នឹងត្រូវធ្វើឡើងដោយសាច់ប្រាក់សុទ្ធ ឬតាមរយៈការផ្ទេរប្រាក់ចូលទៅក្នុងគណនីរបស់មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រផ្ទាល់ បន្ទាប់ពីការវាយតំលៃលើការអនុវត្តន៍សកម្មភាពការងារ ដោយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ពោកោង នៅចុងបញ្ចប់នៃរដូវស្រោចស្រព។

**ប្រការ ៤ ឯកសារផ្សេងៗ និងរបាយការណ៍បញ្ចប់ការអនុវត្តន៍សកម្មភាពការងារ**

ក្រោយពេលបញ្ចប់កិច្ចសន្យារយៈពេលពីរសប្តាហ៍ មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រនឹងផ្តល់របាយការណ៍បញ្ចប់ការអនុវត្តន៍សកម្មភាពការងារតាមកិច្ចសន្យាជូនគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ពោកោង។

**ប្រការ ៥ ការវាយតំលៃលើការអនុវត្តន៍គម្រោង**

ការវាយតំលៃលើការអនុវត្តន៍សកម្មភាពការងារ ដោយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ពោកោងត្រូវធ្វើនៅចុងបញ្ចប់រដូវស្រោចស្រព។

ការវាយតំលៃនេះ ផ្តោតសំខាន់ទៅលើពីរចំណុចៈ

- ការសំរេចនូវគោលបំណង ដូចមានចែងក្នុងប្រការ១
- ធ្វើការឆ្លុះបញ្ចាំងលើនិតិវិធីនៃកិច្ចសហការក្នុងការអនុវត្តន៍ការងារកន្លងមក ដើម្បីស្វែងរកចំណុចល្អ និងចំណុចត្រូវកែលំអសំរាប់អនុវត្តទៅថ្ងៃអនាគត។

**ប្រការ ៦ ការដោះស្រាយទំនាស់**

ករណីមានទំនាស់កើតឡើងពាក់ព័ន្ធនិងកិច្ចសន្យានេះ ភាគីទាំងពីរ នឹងជួបពិភាក្សាគ្នាដើម្បីរកដំណោះស្រាយសមស្របមួយដែលអាចទទួលបានការឯកភាពពីភាគីទាំងពីរ។ ករណីមិនអាចពិភាក្សា រវាងភាគីទាំងពីរ ទំនាស់នេះ នឹងបញ្ជូនទៅដោះស្រាយនៅតុលាកម្ពុជា។

**ប្រការ ៧ សុពលភាពនៃកិច្ចសន្យា**

កិច្ចសន្យានេះ នឹងមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខា រវាងគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រស្ពោកោង និងតំណាងមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ។

**ប្រការ ៨ ការធ្វើវិសោធនកម្មនៃកិច្ចសន្យា**

កិច្ចសន្យានេះ អាចនឹងត្រូវធ្វើការកែប្រែ ករណីមានការឯកភាពទាំងពីរភាគី រវាងគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ពោកោង និងតំណាងមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ។

*ធ្វើនៅ ស្ពោកោង ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១*

*មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ*
*អ្នកសម្របសម្រួល*

**សេង សុភ័គ**

*គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក*
*ប្រព័ន្ធធារាសាស្ត្រស្ពោកោង*
*ប្រធាន*

**ស៊ឹម ស្រួយ**